នស / រកម / ០៧៩៩ / ០៦

# ព្រះរាជក្រម

## យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣

-បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្ម មាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការចាត់-តាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី ស្តីពីការជំរុញ និងការការពារវិនិយោគ ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ១៩៩៩ នាសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី២ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាម លើទំរង់ និងគតិនៃច្បាប់នេះទាំងស្រុង នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គ លើកទី១ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅ :

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រម
# លើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាល
# នៃព្រះរាជាណាចក្រកម្ពុជា
# និងរាជរដ្ឋាភិបាល នៃសាធារណរដ្ឋសិង្ហបុរី
# ស្តីពីការជំរុញ និងការការពារវិនិយោគ

# ច្បាប់

## ស្ដីពី

## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាល
## នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋ
## សិង្ហបុរី ស្ដីពីការជំរុញ និងការការពារវិនិយោគ

មាត្រា ១.-

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសិង្ហបុរី ស្ដីពីការជំរុញ និងការការពារវិនិយោគ ដែលធ្វើនៅភ្នំពេញ នាថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៩៦ ហើយដែលមានអត្ថបទ ទាំងស្រុងភ្ជាប់មកជាមួយ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៩

ក្នុងព្រះបរមនាម និងតាមព្រះរាជបង្គាប់

ប្រមុខរដ្ឋ ស្ដីទី

ហត្ថលេខា

ជា ស៊ីម

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជំរាបជូនសម្ដេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខៈ ១៥៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ១៩៩៩

អគ្គលេខាធិការទីស្ដីការរដ្ឋាភិបាល

ជិនគេន

# កិច្ចព្រមព្រៀង

# រវាង

# រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

# និង

# រដ្ឋាភិបាលនៃសាធារណៈរដ្ឋសិង្ហបុរី

# ស្តីអំពី

# ការជំរុញ និង ការការពារវិនិយោគ

# កិច្ចព្រមព្រៀង

# រវាង

# រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

# និង

# រដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី

# ស្តីអំពី

# ការជំរុញ និង ការការពារវិនិយោគ

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី (ចាប់ពីពេលនេះតទៅរដ្ឋាភិបាលនីមួយៗត្រូវបានគេហៅថាជា « ភាគីកិច្ចសន្យា ») ។

ក្នុងបំណងបង្កើតលក្ខខណ្ឌអនុគ្រោះដល់ការពង្រីកកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច រវាងរដ្ឋាភិបាលទាំងពីរ និង ជាពិសេសគឺសំរាប់វិនិយោគ របស់ជនជាតិ និង ក្រុមហ៊ុនទាំងរបស់រដ្ឋមួយក្នុងទឹកដីនៃរដ្ឋមួយទៀត ដោយឈរលើមូលដ្ឋាននៃគោលការណ៍សមភាព និង ផលប្រយោជន៍ទៅវិញទៅមក

ដោយទទួលស្គាល់ថា ការជំរុញ និង ការការពារទៅវិញទៅមកនូវវិនិយោគទាំងនោះ នឹងអាច ជួយជំរុញ ផ្តួចផ្តើមផ្នែកពាណិជ្ជកម្មព្រមទាំងជំរុញវិបុលភាពនៅក្នុងរដ្ឋទាំងពីរ

រដ្ឋាភិបាលនៃប្រទេសទាំងពីរបានព្រមព្រៀងគ្នាតាមលក្ខខណ្ឌនៃមាត្រាជាបន្តបន្ទាប់នេះ ៖

## មាត្រា១

## និយមន័យ៖

នៅក្នុងគោលបំណងនៃកិច្ចព្រមព្រៀងនេះ

១. ពាក្យថា «វិនិយោគ» គឺនិយាយសំដៅរាល់ប្រភេទនៃទ្រព្យសម្បត្តិដែលអនុញ្ញាតិដោយភាគីកិច្ចសន្យានីមួយៗ ដោយអនុលោមទៅតាមច្បាប់និងបទបញ្ញត្តិរបស់ភាគីនោះៗ និងត្រូវរាប់បញ្ចូលតែមិនកំរិតត្រឹមប្រភេទនៃទ្រព្យសម្បត្តិដូចខាងក្រោមនេះ ៖

(ក) ចលនៈ និង អចលនៈទ្រព្យព្រមទាំងសិទ្ធិជាកម្មសិទ្ធិដទៃៗទៀតមានដូចជាកិច្ចសន្យាដាក់បញ្ចាំសិទ្ធិឃាត់ទុក ឬ ការដាក់វត្ថុបញ្ចាំ ។

(ខ) ភាគហ៊ុន សញ្ញាប័ណ្ណ ប័ណ្ណបំណុល ហើយនិងផលប្រយោជន៍ដែលស្រដៀងគ្នានេះនៅក្នុងក្រុមហ៊ុន ។

(គ) សិទ្ធិទាមទារប្រាក់ ឬ សិទ្ធិដំណើរការក្នុងលក្ខខណ្ឌនៃកិច្ចសន្យាដែលមានតម្លៃជាទឹកប្រាក់ ។

(ឃ) សិទ្ធិនៃកម្មសិទ្ធិបញ្ញា និងកេរ្តិ៍ឈ្មោះជំនួញ ។

(ង) សម្បទានពាណិជ្ជកម្មដែលផ្តល់អោយដោយច្បាប់ ឬ ក្នុងលក្ខខណ្ឌនៃកិច្ចសន្យាដោយរាប់បញ្ចូលនូវសម្បទាននៅក្នុងការស្រាវជ្រាវ ការអភិវឌ្ឍ ការធ្វើនិស្សារណកម្ម ឬ អាជីវកម្មលើធនធានធម្មជាតិ ។

២. ពាក្យថា « ប្រាក់ចំណូល » គឺសំដៅ ចំណូលរូបិយវត្ថុដែលបានពីកិច្ចការវិនិយោគរួមមាន ប្រាក់ចំនេញ ប្រាក់ការ កំណើនដើមទុន ប្រាក់ចំណេញតាមហ៊ុន ប្រាក់ចំណូលពីការលក់ស្នាដៃ ឬ ថ្លៃឈ្នួលនានា ។

៣. ពាក្យថា «ជនជាតិ » គឺសំដៅ÷

(ក) ចំពោះព្រះរាជាណាចក្រកម្ពុជាៈបុគ្គលដែលជាពលរដ្ឋ ឬ ជាជនជាតិដែលស្ថិតក្នុងអធិបតេយ្យភាព នៃទឹកដីរបស់ខ្លួន ។

(ខ) ចំពោះសាធារណរដ្ឋសិង្ហបុរីៈ ពលរដ្ឋសិង្ហបុរីណាដែលស្ថិតក្នុងលក្ខខណ្ឌនៃអត្ថន័យរបស់រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋសិង្ហបុរី ។

៤. ពាក្យថា « ក្រុមហ៊ុន » គឺសំដៅ÷

(ក) ចំពោះព្រះរាជាណាចក្រកម្ពុជាៈ ក្រុមហ៊ុន ដៃគូ ឬ សមាគម ដែលត្រូវបានរៀបចំឡើងជាសាជីវកម្ម ឬ រួមបង្កើតឡើងនៅក្រោមច្បាប់ជាធរមាននៅក្នុងទឹកដីរបស់ខ្លួន ។

(ខ) ចំពោះសាធារណរដ្ឋសិង្ហបុរីៈ ក្រុមហ៊ុន សមាគម ឬ អង្គភាពណាមួយក៏ដោយ ទោះបីជាមាន ឬ គ្មានលក្ខណៈ សម្បត្តិជានីតិបុគ្គល ដែលត្រូវបានបង្កើតឡើងតាមបែបបទសាជីវកម្ម ឬ ត្រូវបានបង្កើតឡើង និងកត់ត្រាក្នុងបញ្ជីដោយគោរពទៅតាមច្បាប់ជាធរមាននៅក្នុងសាធារណរដ្ឋសិង្ហបុរី ។

៥. ពាក្យថា « ទឹកដី » គឺសំដៅ÷

(ក) ចំពោះព្រះរាជាណាចក្រកម្ពុជា ដែនគោក ដែនសមុទ្រ ដែនដី បាតសមុទ្រ និង ដែនអាកាស ។

(ខ) ចំពោះសាធារណរដ្ឋសិង្ហបុរីៈដែនគោក ដែនសមុទ្រ ដែនដី បាតសមុទ្រ និង ដែនអាកាស

៦. ពាក្យថា « រូបិយប័ណ្ណដែលអាចប្តូរបានដោយសេរី » គឺសំដៅរូបិយប័ណ្ណណាដែលត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយ សំរាប់ការទូទាត់លុយនៅក្នុងកិច្ចការជំនួញអន្តរជាតិ និង ត្រូវបានគេប្តូរជាទូទៅនៅក្នុងទីផ្សាររូបិយវត្ថុសំខាន់ៗ ។

## មាត្រា ២ ÷
## អនុវត្តន៍នៃកិច្ចព្រមព្រៀង

១. កិច្ចព្រមព្រៀងនេះនឹងត្រូវអនុវត្តតែក្នុងលក្ខខណ្ឌខាងក្រោម ÷

(ក) ចំពោះសកម្មភាពវិនិយោគនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា គឺត្រូវអនុវត្តចំពោះគ្រប់វិនិយោគរបស់ជនជាតិ និង ក្រុមហ៊ុននៃសាធារណរដ្ឋសិង្ហបុរី ដែលត្រូវបង្កើតឡើងដោយអនុលោមទៅតាម ច្បាប់ ឬ បទបញ្ញត្តិរបស់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង ដោយអាស្រ័យទៅលើ លក្ខខណ្ឌទាំងឡាយណា ដែលគេពិចារណាឃើញថាសមស្រប ។

(ខ) ចំពោះវិនិយោគនៅក្នុងទឹកដីនៃសាធារណរដ្ឋសិង្ហបុរី គឺត្រូវអនុវត្តចំពោះរាល់សកម្មភាពវិនិយោគ ដែលធ្វើឡើងដោយជនជាតិ និង ក្រុមហ៊ុននៃព្រះរាជាណាចក្រកម្ពុជា តាមការព្រមព្រៀងជាក់លាក់ និង ជាលាយល័ក្ខអក្សររបស់អាជ្ញាធរមានសមត្ថកិច្ច ដែលត្រូវបានតែងតាំងដោយរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរីនិងដោយអាស្រ័យ ទៅលើលក្ខខណ្ឌទាំងឡាយណាប្រសិនបើគេ ពិចារណាឃើញថាសមស្រប ។

២. ន ទាំងឡាយដែលបានចែងនៅក្នុងកថាខណ្ឌខាងដើម គឺត្រូវអនុវត្តចំពោះរាល់វិនិយោគដែលធ្វើឡើងដោយជនជាតិ និង ក្រុមហ៊ុននៃភាគីកិច្ចសន្យាមួយនៅក្នុងទឹកដីនៃភាគីកិច្ចសន្យាមួយទៀត ទោះបីបើវិនិយោគត្រូវបាន ធ្វើឡើងនៅមុនពេល ឬ ក្រោយពេលការចូលជាធរមាននៃកិច្ចព្រមព្រៀង ។

## មាត្រា ៣÷
## ការជំរុញ និង ការការពារវិនិយោគ

១. ភាគីកិច្ចសន្យានីមួយៗត្រូវលើកទឹកចិត្ត និង បង្កើតលក្ខខណ្ឌអនុគ្រោះដល់ជនជាតិ និង ក្រុមហ៊ុននៃភាគីកិច្ចសន្យាម្ខាងទៀតដែលធ្វើវិនិយោគនៅក្នុងទឹកដីរបស់ខ្លួនដោយអនុលោមតាមគោល នយោបាយសេដ្ឋកិច្ចជាទូទៅ របស់ខ្លួន ។

២. វិនិយោគដែលបានអនុវត្តក្នុងមាត្រា២ នឹងត្រូវទទួលប្រព្រឹត្តកិច្ច និង ការការពារប្រកបដោយយុត្តិធម៌ និង សមធម៌ ស្របទៅនឹងកិច្ចព្រមព្រៀងនេះ ។

## មាត្រា ៤៖

## លក្ខខណ្ឌនៃការផ្តល់សព្វាគ្គី ដែលអនុគ្រោះបំផុត

នៅក្នុងទឹកដីរបស់ខ្លួនពុំមានភាគីកិច្ចសន្យាណាមួយមានសិទ្ធិផ្តល់នូវប្រព្រឹត្តិកិច្ចចំពោះវិនិយោគ ដែលត្រូវបានអនុញ្ញាតតាមលក្ខខណ្ឌនៃមាត្រា២ ឬ ចំពោះប្រាក់ចំណូលរបស់ជនជាតិ និង ក្រុមហ៊ុននៃភាគីកិច្ចសន្យាម្ខាងទៀត តិចជាងអ្វីដែលបានផ្តល់ផលវិនិយោគ ឬ ប្រាក់ចំណូលរបស់ជនជាតិ និង ក្រុមហ៊ុននៃប្រទេសទីពណាទៀតឡើយ ។

## មាត្រា ៤៖

## ករណីលើកលែង

១. ខទាំងឡាយណាដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ដែលពាក់ព័ន្ធទៅនឹងការផ្តល់ប្រព្រឹត្តកិច្ចដែលត្រូវផ្តល់នូវលក្ខណៈអនុគ្រោះមិនតិចជាងអ្វីដែលត្រូវបានផ្តល់ទៅអោយជនជាតិ និង ក្រុមហ៊ុនភាគីរដ្ឋទីពមិនត្រូវ យកមកបកស្រាយ ដើម្បីតំរូវអោយភាគីកិច្ចសន្យាម្ខាងផ្តល់ផលជនជាតិ និង ក្រុមហ៊ុននៃភាគីកិច្ចសន្យាម្ខាង ទៀតនូវអត្ថប្រយោជន៍នៃប្រព្រឹត្តកិច្ច អាទិភាព ឬ ឯកសិទ្ធិដែលបានមកពី៖

(ក) កិច្ចព្រមព្រៀងក្នុងតំបន់សហប្រតិបត្តិការ គយ បរិយវត្ថុ ពន្ធនីយភាព ឬ កិច្ចការពារពិធីកម្មដទៃទៀត ( ដោយរាប់បញ្ចូលតំបន់ពាណិជ្ជកម្មសេរី ) ឬ កិច្ចព្រមព្រៀងអន្តរជាតិដែលត្រូវបានគេរៀបចំពេលឡើងដោយតំបន់ខ្លះនៃផលកិច្ចព្រមព្រៀងក្នុងតំបន់ណាមួយនាពេលអនាគត ។

(ខ) ការព្រមព្រៀងណាមួយដែលធ្វើឡើងជាមួយរដ្ឋទីព ឬ រដ្ឋនានានៅក្នុងតំបន់ភូមិសាស្រ្តតែមួយ និងដែលធ្វើឡើងក្នុងទិសដៅជម្រុញកិច្ចសហប្រតិបត្តិការក្នុងតំបន់នៅក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច ពលកម្មឧស្សាហកម្ម ឬ បរិយាប័ណ្ណ ក្នុងក្របខ័ណ្ឌគំរោងដែលបានកំណត់យ៉ាង ជាក់លាក់ ។

២. របត្តិ៍ញ្ញុទាំងឡាយនៃកិច្ចព្រមព្រៀងនេះ និងមិនត្រូវអនុវត្តចំពោះកិច្ចការពន្ធដារនៅក្នុងទឹកដីនៃភាគីកិច្ចសន្យាណាមួយឡើយ ។ កិច្ចការនេះត្រូវគ្រប់គ្រងដោយសិទ្ធិសញ្ញាស្តីពីការមិនយកពន្ធត្រួតគ្នារវាងភាគីកិច្ចសន្យា ទាំងពីរ ហើយនិងច្បាប់នៅក្នុងស្រុកនៃភាគីម្ខាងៗ ។

## មាត្រា ៦៖

## ការរឹបអូស

១. គ្មានភាគីកិច្ចសន្យាណាមួយ នឹងត្រូវប្រកាន់យកវិធានការណាមួយសំរាប់រឹបអូសទ្រព្យសម្បត្តិតាមផ្លូវច្បាប់ ជាតូបនីយកម្ម ឬ វិធានការផ្សេងៗទៀតដែលមានឥទ្ធិពលស្មើគ្នានឹងជាតូបនីយកម្ម ឬការរឹបអូស ( ពីនេះត ទៅហៅថា « ការរឹបអូស » ) វិនិយោគរបស់ជនជាតិ ឬ ក្រុមហ៊ុននៃភាគីកិច្ចសន្យា ម្ខាង លើកលែងតែវិធានការនេះត្រូវបានអនុញ្ញាតិដោយច្បាប់ដោយគ្មានការរើសអើង និង ដោយអនុលោមទៅតាមច្បាប់របស់ភាគីនោះ ហើយដោយមានវិធានការទូទាត់សំណងដ៏ត្រឹមត្រូវ និង គ្មានការពន្យាពេលដែលមិន សមហេតុផលឡើយ ។

ក្នុងករណីនៃសាធារណរដ្ឋសិង្ហបុរីការទូទាត់បែបនេះ ដោយស្របទៅនឹងច្បាប់របស់គេគឺជាតម្លៃភ្លាមៗ មុនពេលនៃការរឹបអូសនេះ ។

ក្នុងករណីសំរាប់ព្រះរាជាណាចក្រកម្ពុជា តម្លៃនៃវិនិយោគដែលត្រូវបានរឹបអូសគឺត្រូវតែជាតម្លៃទីផ្សារ តាមការកំណត់របស់អ្នកវាយតំលៃអន្តរជាតិដែលឯករាជ្យ និង ត្រូវបានជ្រើសតាំងឡើងដោយការព្រមព្រៀងទៅវិញទៅមកនៃភាគីកិច្ចសន្យាទាំងពីរ ។ ការទូទាត់នឹងអាចផ្លាស់ប្តូរ និង ផ្ទេរដោយសេរី ។

២. វិធានការរឹបអូសដោយ សំរាប់ការរឹបអូស ឬ ការវាយតំលៃអោយតម្លៃការអស់របស់ជនជាតិ ឬ ក្រុមហ៊ុន ដែលទ្រព្យត្រូវបានរឹបអូសដោយមានការត្រួតពិនិត្យពីតុលាការ ឬ អាជ្ញាធរឯករាជ្យផ្សេងទៀត នៃភាគីកិច្ចសន្យា ដែលត្រូវរៀបចំវិធានការតាមទម្រង់បញ្ញត្តិនៃច្បាប់របស់ភាគីនោះ ។

៣. ក្នុងករណីដែល ភាគីកិច្ចសន្យាមួយរឹបអូសនូវទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនណាមួយដែលត្រូវបានរៀបចំជាសាជីវកម្ម ឬ បង្កើតឡើងនៅពីក្រោមច្បាប់ជាធរមានក្នុងតំបន់ណាមួយនៃទឹកដីរបស់គេផ្ទាល់ ហើយនៅក្នុងនោះ មានជនជាតិ ឬ ក្រុមហ៊ុននៃភាគីកិច្ចសន្យាម្ខាងទៀតមានកាន់កាប់ភាគហ៊ុននេះ ភាគីនេះត្រូវធ្វើយ៉ាងណាដើម្បី ធានាថាលក្ខខណ្ឌនៃខទីមួយនៅក្នុងកថាខណ្ឌ ១ នៃមាត្រានេះត្រូវបានអនុវត្តដល់កំរិតចាំបាច់ដើម្បីធានា ចំពោះការទូទាត់ដូចមានចែងក្នុងមាត្រានេះទៅលើជនជាតិ ឬ ក្រុមហ៊ុននៃភាគីកិច្ចសន្យាម្ខាងទៀតដែលជា ម្ចាស់ភាគហ៊ុនទាំងនោះ។

## មាត្រា ៤÷

## ការទូទាត់ចំពោះការខាតបង់

១

ជនជាតិ ឬ ក្រុមហ៊ុននៃភាគីកិច្ចសន្យាម្ខាងដែលវិនិយោគរបស់ខ្លួនត្រូវបានទទួលការខាតបង់ដោយសារតែសង្គ្រាម ឬ ជម្លោះអាវុធ ការប្រកាសភាពអាសន្ន ការបះបោរ ឬ កុប្បកម្ម ដែលកើតមាននៅក្នុងទឹកដីនៃ ភាគីកិច្ចសន្យាម្ខាងទៀតគឺត្រូវទទួលការយល់ព្រមផ្តល់ប្រព្រឹត្តកិច្ចដោយភាគីកិច្ចសន្យា ដែលជាម្ចាស់ទឹកដីតាមលក្ខខណ្ឌនៃសំណង ការបាត់បង់ ការទូទាត់ ឬ ដំណោះស្រាយណាមួយផ្សេងពីនេះប្រសិនបើមាន ដែលមានលក្ខណៈអនុគ្រោះដែលមិនតិចជាងប្រព្រឹត្តកិច្ចដែលភាគីកិច្ចសន្យានេះព្រមព្រៀងផ្តល់ដល់ជនជាតិ ឬ ក្រុមហ៊ុននៃរដ្ឋទីបីណាមួយឡើយ ។

ការទូទាត់សំណងណាមួយក៏ដោយដែលជាលទ្ធផលនៃហេតុការខាងលើគឺអាចផ្លាស់ប្តូរ និងផ្ទេរបានដោយសេរី ។

## មាត្រា ៥÷

## ផ្ទេរ

១. ភាគីកិច្ចសន្យាម្ខាងត្រូវធានាចំពោះជនជាតិ ឬ ក្រុមហ៊ុនរបស់ភាគីកិច្ចសន្យាម្ខាងទៀតអំពីការផ្ទេរដោយសេរី ដោយគ្មានការរើសអើងនូវប្រាក់ទុនហើយនិងប្រាក់ចំណេញដែលបានមកពីវិនិយោគ ។ ការផ្ទេរទាំងអស់នេះត្រូវ ធ្វើឡើងដោយប្រើប្រាស់រូបិយប័ណ្ណដែលអាចដូរបានដោយសេរី ដោយគ្មានការរឹតត្បិត ឬ ការពន្យារពេលដោយគ្មានមូលហេតុ ។ បទប្បញ្ញត្តិនេះនឹងត្រូវការបញ្ចូលទាំងពិសេស [illegible]៖

(ក) ប្រាក់ចំណេញ កំណើនប្រាក់ទុន ប្រាក់ចំណេញភាគហ៊ុន ប្រាក់បង់ថ្លៃឈ្នួល ការប្រាក់ និង ចំណូល ផ្សេងៗ ទៀត ដែលបានពីវិនិយោគ ។

(ខ) ប្រាក់ចំណូលដែលបានពីការលក់វិនិយោគទាំងអស់ ឬ តាមផ្នែក ។

(គ) សំណងដែលត្រូវធ្វើឡើងដោយផ្អែកទៅលើកិច្ចព្រមព្រៀងប្រាក់កម្ចី ដែលពាក់ព័ន្ធនៅក្នុងកិច្ចការ វិនិយោគ ។

(ឃ) ថ្លៃអាជ្ញាប័ណ្ណដែលពាក់ព័ន្ធទៅនឹងសិទ្ធិដែលបានកំណត់នៅក្នុងមាត្រា ១ (ក) (ឃ) ។

(ង) [illegible]

(ច) [illegible]

(គ) ចំណូលរបស់ជនជាតិ ឬ ភាគីកិច្ចសន្យាម្ខាងទៀតដែលធ្វើការងារក្នុងទំនាក់ទំនងជាមួយវិនិយោគនៅក្នុង ដែនដីរបស់ភាគីកិច្ចសន្យា ។

២. គ្មានលក្ខខណ្ឌណាមួយនៅក្នុងកថាខណ្ឌ ១ នៃមាត្រានេះ អាចត្រូវបានគេយកទៅប្រើសម្រាប់ការទូទាត់ទឹកប្រាក់ដែលត្រូវបង់ដោយគោរពទៅតាមមាត្រា ៦ និង ៧ នៃកិច្ចព្រមព្រៀងនេះទេ ។

## មាត្រា ៩÷
## អត្រាប្តូរប្រាក់

ការផ្ទេរដែលត្រូវបានអះអាងនៅក្នុងមាត្រា ៦ ដល់ ៨ នៃកិច្ចព្រមព្រៀងនេះនឹងត្រូវអនុវត្តតាមអត្រាទីផ្សារជាក់ស្តែងដោយប្រើប្រាស់រូបិយប័ណ្ណដែលអាចដូរបានដោយសេរីនៅក្នុងពេលផ្ទេរ ។

## មាត្រា ១០÷
## ច្បាប់

ដើម្បីជៀសវាងនូវការសង្ស័យណាមួយ គេសូមប្រកាសថាការវិនិយោគក្នុងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះនឹងត្រូវបានគ្រប់គ្រងដោយច្បាប់ជាធរមាន នៅក្នុងដែនដីនៃភាគីកិច្ចសន្យាដែលសកម្មភាពវិនិយោគត្រូវបានប្រព្រឹត្តទៅ ។

## មាត្រា ១១÷
## ការហាមឃាត់ និង ការដាក់លក្ខខណ្ឌ

ខទាំងឡាយណា ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះនឹងមិនត្រូវកំណត់សិទ្ធិរបស់ភាគីកិច្ចសន្យាណាមួយនៅក្នុងការហាមឃាត់ ឬ ដាក់លក្ខខណ្ឌ ឬ ការប្រកាន់យកនូវសកម្មភាពផ្សេងពីនេះដែលសំដៅទៅលើការការពារផលប្រយោជន៍ផ្នែកសន្តិសុខដ៏ចាំបាច់របស់ខ្លួន ឬ ការការពារសុខភាពសាធារណៈ ឬ ការទប់ស្កាត់ជំងឺសត្វ និង រុក្ខជាតិ ។

## មាត្រា ១២៖

## សិទ្ធិផ្ទេរបន្ត

១. ក្នុងព្រឹត្តិការណ៍ដែលភាគីកិច្ចសន្យាណាមួយ ( ឬ ភ្នាក់ងារ ស្ថាប័ន អង្គភាពដែលមានលក្ខន្តិកៈតាមច្បាប់ ឬ សាជីវកម្មដែលត្រូវបានតែងតាំងដោយភាគីកិច្ចសន្យានេះ) ក្នុងលក្ខខណ្ឌនៃសំណងដែលត្រូវបានផ្តល់តាម លក្ខខណ្ឌវិនិយោគ ឬ ផ្នែកណាមួយនៃវិនិយោគដោយបង់សងដល់ជនជាតិ និង ក្រុមហ៊ុនរបស់ខ្លួនផ្ទាល់តាមការ ទាមទាររបស់គេណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ នោះភាគីកិច្ចសន្យាមួយទៀតត្រូវទទួលស្គាល់ថាភាគីកិច្ចសន្យា ដែលបានចែងខាងលើនេះ ( ឬ ភ្នាក់ងារ ស្ថាបន អង្គភាពដែលមានលក្ខន្តិកៈតាមច្បាប់ ឬ សាជីវកម្ម ដែល ត្រូវបានតែងតាំងដោយភាគីកិច្ចសន្យានេះ ) មានសិទ្ធិតាមក្របខ័ណ្ឌនៃសិទ្ធិផ្ទេរបន្ត ប្រើប្រាស់ និង អះអាងសិទ្ធិរបស់ ជនជាតិ និង ក្រុមហ៊ុនរបស់គេ ។

សិទ្ធិដែលត្រូវបានផ្ទេរបន្ត ឬ ការទាមទារនឹងមិនត្រូវអោយមានច្រើនជាងសិទ្ធិ ឬ ការទាមទារខាងដើមរបស់អ្នក វិនិយោគ ដូចដែលបានពោលរួចមកហើយនោះទេ ។

២. សំណងណាមួយក៏ដោយដែលទទួលឡើងដោយភាគីកិច្ចសន្យាមួយ ( ឬ ភ្នាក់ងារ ស្ថាប័ន អង្គភាព ដែលមានលក្ខន្តិកៈតាមច្បាប់ ឬ សាជីវកម្មដែលត្រូវបានតែងតាំងដោយភាគីកិច្ចសន្យានេះ ) ចំពោះជនជាតិ និង ក្រុមហ៊ុនរបស់ខ្លួនគឺមិនត្រូវប៉ះពាល់ដល់សិទ្ធិរបស់ជនជាតិ និង ក្រុមហ៊ុនក្នុងការប្តឹងភាគីកិច្ចសន្យាមួយទៀត ដោយអនុលោមតាមមាត្រា ១៣ ។

## មាត្រា ១៣៖

## ជំលោះវិនិយោគ

១. ជំលោះណាក៏ដោយ ដែលកើតមានរវាងជនជាតិ និង ក្រុមហ៊ុននៃភាគីកិច្ចសន្យាមួយ និង ភាគីនៃកិច្ចសន្យាមួយទៀត ដែលទាក់ទងជាមួយវិនិយោគនៅលើទឹកដីនៃភាគីកិច្ចសន្យាម្ខាងទៀតនឹងត្រូវដោះស្រាយអោយអស់លទ្ធភាព និង ដោយបេក្ខភាពតាមរយៈការចរចាររវាងភាគីដែលមានជំលោះ ។ ភាគីដែលអោយបំណងដោះស្រាយជំលោះបែបនេះ តាមការចរចាត្រូវផ្តល់ពិនិត្យជាផ្លូវការដល់ភាគីដែលត្រូវចូលរួមដោះស្រាយ ។

២. ប្រសិនបើជំលោះណាមួយមិនអាចត្រូវបានដោះស្រាយតាមលក្ខខណ្ឌដូចដែលបានកំណត់ក្នុងកថាខណ្ឌ ១ នៃ កិច្ចព្រមព្រៀងនេះ នៅក្នុងរយៈពេលប្រាំមួយខែគិតចាប់ពីថ្ងៃដែលពិនិត្យជាផ្លូវការត្រូវបានផ្តល់ ដោយភាគីណាមួយ ដែលស្ថិតក្នុងជំលោះនោះ ហើយពុំមានការព្រមព្រៀងផ្សេងពីភាគីទាំងពីរនេះទេ និង

ដោយអាស្រ័យទៅលើសំណើរ របស់ភាគីទាំងសងខាងជំលោះនោះនឹងត្រូវដាក់អោយពិនិត្យសំរេចតាមរយៈ÷

(ក) ការផ្សះផ្សា ឬ អាជ្ញាកណ្តាលដែលរៀបចំឡើងដោយមជ្ឈមណ្ឌលអន្តរជាតិសំរាប់ដំណោះស្រាយជំលោះ វិនិយោគ ( ហៅថា« មជ្ឈមណ្ឌល » ក្នុងកិច្ចព្រមព្រៀងនេះ ) ដែលត្រូវបានបង្កើតឡើងដោយសន្ធិបាតស្តីអំពីដំណោះស្រាយវិនិយោគរវាងរដ្ឋ ហើយនឹងជនជាតិនៃរដ្ឋនានា ដែលបើកចំហរចំពោះការចុះ ហត្ថលេខានៅក្នុងទីក្រុងវ៉ាស៊ីនតោន កាលពីថ្ងៃទី ១៨ ខែមិនាឆ្នាំ១៩៦៥ (ហៅថា «សន្ធិបាត »ក្នុងកិច្ចព្រមព្រៀងនេះ ) ។ ក្នុងគោលបំណងនេះភាគីកិច្ចសន្យានីមួយៗបានយល់ព្រមជាមុននិងមិនកែប្រែនូវក្នុងការដាក់ជំលោះអោយមជ្ឈមណ្ឌលពិនិត្យសំរេចស្របតាមមាត្រា ២៥ នៃ សន្ធិបាត ។

(ខ) អាជ្ញាកណ្តាល ១ រូបនៃសាលាជំរះក្តីអាជ្ញាកណ្តាលអន្តរជាតិ « អាត់ហុក »ត្រូវបានរៀបចំឡើងតាម លក្ខខ័ណ្ឌនៃបទបញ្ញត្តច្បាប់អាជ្ញាកណ្តាលរបស់គណៈកម្មការសហប្រជាជាតិសំរាប់ច្បាប់ពាណិជ្ជកម្ម អន្តរជាតិ (UNCITRAL )។ ភាគីនានាដែលបានចូលរួមក្នុងជំលោះស្រាយជំលោះអាចផ្តល់ការ យល់ព្រមតាមសំនើរ ដើម្បីកែប្រែបទបញ្ញត្តទាំងនេះ ។ ការសំរេចរបស់អាជ្ញាកណ្តាលនឹងត្រូវបានចាត់ទុក ថា ដាច់ព្រាត់ហើយមានប្រសិទ្ធភាពលើភាគីទាំងសងខាងនៃជំលោះនោះ ។

## មាត្រា ១៥÷
## ជំលោះរវាងភាគីកិច្ចសន្យា

១. ជំលោះណាមួយក៏ដោយដែលកើតមានរវាងភាគីកិច្ចសន្យានៅក្នុងបំណកស្រាយ ឬ ការអនុវត្តកិច្ចព្រមព្រៀងនេះនឹងត្រូវបានធ្វើការដោះស្រាយដោយអស់លទ្ធភាពតាមរយៈការចរចា ។

២. ប្រសិនបើជំលោះណាមួយមិនអាចត្រូវបានដោះស្រាយតាមរបៀបនេះទេ ជំលោះនោះនឹងត្រូវបានដាក់អោយអាជ្ញាកណ្តាលពិនិត្យសំរេចដោយផ្អែកទៅតាមសំណើររបស់ភាគីណាមួយ ។ សាលាក្តីអាជ្ញាកណ្តាល (ដែលចាប់ពីពេលនេះតទៅត្រូវគេហៅថា «សាលាក្តី » ) នឹងត្រូវមានអាជ្ញាកណ្តាល៣រូបដោយភាគីកិច្ចសន្យានីមួយៗតែងតាំងអាជ្ញាកណ្តាលរបស់ខ្លួន ហើយអាជ្ញាកណ្តាលទី៣ដែលត្រូវធ្វើជាប្រធានរបស់សាលាក្តីនេះគឺ ត្រូវតែងតាំងដោយការព្រមព្រៀងរបស់ភាគីកិច្ចសន្យា ។

៣. ក្នុងកំឡុងពេលពីរខែនៃការទទួលសំណើរដើម្បីដោះស្រាយជំលោះតាមរយៈអាជ្ញាកណ្តាល ភាគីកិច្ចសន្យានីមួយៗត្រូវតែងតាំងអាជ្ញាកណ្តាល១រូបរបស់ខ្លួន ហើយនៅក្នុងអំឡុងពេលពីរខែនៃការតែងតាំងអាជ្ញាកណ្តាល ទាំងពីរនេះ ភាគីកិច្ចសន្យាត្រូវតែងតាំងអាជ្ញាកណ្តាលទីពោ

៤. ប្រសិនបើសាលាក្តីមិនត្រូវបានរៀបចំបង្កើតឡើង នៅក្នុងអំឡុងពេលបួនខែនៃការទទួលសំណើរបង្កើត អាជ្ញាកណ្តាល ក្នុងលក្ខខណ្ឌដែលគ្មានកិច្ចព្រមព្រៀងណាមួយផ្សេងពីនេះ ភាគីកិច្ចសន្យាទិមួយៗអាច អញ្ជើញប្រធានតុលាការយុត្តិធម៌អន្តរជាតិអោយធ្វើការតែងតាំងអាជ្ញាកណ្តាល១រូប ឬ ច្រើនរូបដែល មិនទាន់ត្រូវបានតែងតាំង ។ ប្រសិនបើប្រធាននោះមានសញ្ជាតិដូចគ្នាទៅនឹងភាគីកិច្ចសន្យាណាមួយ ឬ ប្រសិនបើប្រធាននោះពុំមានសមត្ថភាពនឹងបំពេញកិច្ចការបែបនេះ អនុប្រធានអាចត្រូវបានគេអញ្ជើញ អោយបំពេញកិច្ចការនេះ ។ ប្រសិន បើ អនុប្រធាន មានសញ្ជាតិដូចគ្នាទៅនឹងភាគីកិច្ចសន្យាណាមួយ ឬ ពុំមានសមត្ថភាពនឹងបំពេញកិច្ចការបែបនេះ សមាជិក១រូប នៃតុលាការយុត្តិធម៌អន្តរជាតិដែល ចាស់វស្សាជាងគេ និង ដែលពុំមានសញ្ជាតិដូចគ្នាទៅនឹងភាគី ណាមួយអាចត្រូវបានគេអញ្ជើញអោយ ទទួលការតែងតាំងនេះ ។ល។

៥. សាលាក្តីត្រូវធ្វើសេចក្តីសំរេចរបស់ខ្លួនតាមសន្លឹកឆ្នោតភាគច្រើន ។

៦. សេចក្តីសំរេចរបស់សាលាក្តីត្រូវមានប្រសិទ្ធភាពដាច់ព្រាត់ ហើយភាគីកិច្ចសន្យាត្រូវគោរពនឹងធ្វើតាម លក្ខខណ្ឌទាំងឡាយនៃសេចក្តីសំរេចនេះ ។

៧. ភាគីកិច្ចសន្យាទិមួយៗត្រូវរ៉ាប់រងសោហ៊ុយសំរាប់សមាជិកផ្ទាល់របស់ខ្លួននៅក្នុងសាលាក្តី និង ការតំណាង របស់ខ្លួនក្នុងរឿងអាជ្ញាកណ្តាល ហើយនិងសោហ៊ុយពាក់កណ្តាលសំរាប់ប្រធានព្រមទាំងតម្លៃដែល នៅសេសសល់ ។ តែទោះបីជាយ៉ាងណាក៏ដោយ តាមសេចក្តីសំរេចរបស់ខ្លួនសាលាក្តីអាចកាត់តែង សោហ៊ុយភាគច្រើនអោយរ៉ាប់រងដោយភាគីមួយក្នុងចំណោមភាគីទាំងពីរ ហើយសេចក្តីសំរេចនេះ និងត្រូវមានប្រសិទ្ធភាពលើភាគីទាំងពីរ ។

៨. ក្រៅពីបទបញ្ញត្តិខាងលើ សាលាក្តីនឹងត្រូវរៀបចំបង្កើតបទបញ្ជាគោលនីតិវិធីរបស់ខ្លួនផ្ទាល់ ។

## មាត្រា ១៥៖
## ភាពចុះសម្រុងនៃច្បាប់

ប្រសិនបើច្បាប់នៃភាគីកិច្ចសន្យាណាមួយ ឬ កាតព្វកិច្ចអន្តរជាតិដែលមានស្រាប់មកហើយនិងនៅពេលអនាគត ឬ ត្រូវបានបង្កើតឡើងចាប់ពីពេលនេះតទៅរវាងភាគីកិច្ចសន្យាជាលក្ខណៈ បន្ថែមលើកិច្ចព្រមព្រៀងនេះ ផ្ដល់ ច្បាប់ទូទៅដែលផ្តល់សិទ្ធិអោយវិនិយោគដែលអនុគ្រោះ លើសពីសិទ្ធិនៃភាគីកិច្ចសន្យាមួយផ្សេង ទៀត ចំពោះប្រព្រឹត្តកម្មដែលអនុគ្រោះជាងលក្ខខណ្ឌដែលផ្តល់ដោយកិច្ចព្រមព្រៀងនេះ ច្បាប់បែបនេះនឹង មិនត្រូវធ្វើអោយប៉ះពាល់ដោយកិច្ចព្រមព្រៀងនេះទេ ។ ភាគីកិច្ចសន្យានីមួយៗត្រូវតែប្រតិបត្តិកិច្ចសន្យាដែល ត្រូវបំពេញដោយអនុលោមតាមច្បាប់ដែលបានចែងពីលើលក្ខខណ្ឌផ្សេងៗ ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ

ដែលធ្វើឡើង ដោយភាគីនៃកិច្ចសន្យាណាមួយនិងដោយជនជាតិ ឬ ក្រុមហ៊ុននៃភាគីនោះជាមួយនឹង ជនជាតិ ឬ ក្រុមហ៊ុននៃភាគីកិច្ចសន្យាមួយទៀត លើបញ្ហាពាក់ព័ន្ធទៅនឹងកិច្ចការវិនិយោគរបស់ពួកគេ ។

## មាត្រា ១៦÷

## ការចូលជាធរមាន រយៈកាល និង ការបញ្ចប់

១. ភាគីកិច្ចសន្យានីមួយៗត្រូវផ្តល់ដំណឹងដល់ភាគីកិច្ចសន្យាម្ខាងទៀត ស្តីអំពីការបំពេញនីតិវិធីផ្ទៃក្នុងអន្តរជាតិរបស់ខ្លួនដើម្បីអោយកិច្ចព្រមព្រៀងនេះចូលជាធរមាន ។ កិច្ចព្រមព្រៀងនេះនឹងត្រូវចូលជាធរមាននៅថ្ងៃទី ៣០ គិតចាប់ពីថ្ងៃដែលភាគីកិច្ចសន្យាចុងក្រោយនេះបានផ្តល់ដំណឹង ។

២. កិច្ចព្រមព្រៀងនេះស្ថិតនៅជាធរមានសំរាប់រយៈពេលដប់ (១០) ឆ្នាំ ហើយនឹងត្រូវបន្តពីពេលនោះតទៅទៀត លើកលែងតែបន្ទាប់ពីការផុតកំណត់នៃរយៈកាល១៥ឆ្នាំខាងដើម មានភាគីកិច្ចសន្យាណាមួយផ្តល់ដំណឹងជាលាយល័ក្ខអក្សរដល់ភាគីកិច្ចសន្យាមួយទៀត ស្តីពីគោលបំណងរបស់ខ្លួននៅក្នុងការបញ្ចប់កិច្ចព្រមព្រៀងនេះ ។ សេចក្តីប្រកាសស្តីពីការបញ្ចប់កិច្ចព្រមព្រៀងនឹងត្រូវមានប្រសិទ្ធភាពក្នុងរយៈពេល១ឆ្នាំ បន្ទាប់ពីភាគីកិច្ចសន្យា ម្ខាងទៀតបានទទួលនូវសេចក្តីជូនដំណឹងនេះ ។

៣. ចំពោះវិនិយោគដែលបានបង្កើតឡើង នៅមុនពេលដែលសេចក្តីប្រកាសពីការបញ្ចប់កិច្ចព្រមព្រៀងមានប្រសិទ្ធិភាពបទប្បញ្ញត្តិនៃមាត្រា ១ ដល់ ១៥ នឹងត្រូវស្ថិតនៅជាធរមានក្នុងរយៈពេល១០ឆ្នាំទៀត គិតចាប់ពីពេលនៃការប្រកាសនោះ ។

ដើម្បីជាសាក្សីនៃកិច្ចព្រមព្រៀងនេះ អ្នកតំណាងទាំងឡាយដែលបានចុះហត្ថលេខាខាងក្រោមត្រូវបានរដ្ឋាភិបាលប្រគល់សិទ្ធិអំណាចដ៏ត្រឹមត្រូវរៀងៗខ្លួន នៅក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

ឯកសារនេះត្រូវបានធ្វើជាពីរច្បាប់ដូចគ្នាបេះបិទនៅក្រុងភ្នំពេញថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ 1996 ជាភាសាខ្មែរ និង ភាសាអង់គ្លេស ហើយរាល់អត្ថបទគឺត្រូវមានតំលៃស្មើគ្នា ។ ក្នុងករណីដែលមានបំលាកស្រឡាយខុសគ្នាអត្ថបទភាសាអង់គ្លេសត្រូវប្រកាន់យកអាទិភាព ។

| | |
|---|---|
| រដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី | រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា |